# ប្លង់គោលប្រើប្រាស់ដីក្រុងកែប

## ចក្ខុវិស័យឆ្នាំ២០៣០

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

លេខ: ០០១ សសរ.

ថ្ងៃព្រហស្បតិ៍ ៨ រោច ខែអាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៨

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកែប ខេត្តកែប

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញសេចក្ដីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្ដីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

-យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកែប និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប

## **សម្រេច**

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកែប ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្ដីសម្រេចនេះ។

**ប្រការ ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប ត្រូវរៀបចំផែនការ សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះ ឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីក្រុងកែប ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងកែបមុនពេលកំណត់អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងកែប ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តកែប និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប និងអភិបាលនៃគណៈអភិបាលក្រុងកែបនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

ជា សុផារ៉ា

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ០០១ សសរ ចុះថ្ងៃព្រហស្បតិ៍ ៥ រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ត្រូវនឹងថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨

ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកែប ខេត្តកែប

# ប្លង់គោលប្រើប្រាស់ដីក្រុងកែប

## ចក្ខុវិស័យឆ្នាំ២០៣០

## មាតិកា

ទំព័រ


១-សេចក្តីផ្តើម.....១

២-ចក្ខុវិស័យ.....២

២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម.....២

២.២-ចក្ខុវិស័យ.....៣

៣-គោលបំណង និងគោលដៅ.....៣

៣.១-គោលបំណង.....៣

៣.២-គោលដៅ.....៤

៤-យុទ្ធសាស្រ្តអភិវឌ្ឍន៍ និងអភិរក្សក្រុងកែប.....៤

៤.១-យុទ្ធសាស្រ្តគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព.....៤

៤.១.១-ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម.....៤

៤.១.២-យុទ្ធសាស្រ្តគ្រប់គ្រង និងប្រើប្រាស់ដី.....៥

៤.២-យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យទេសចរណ៍.....៩

៤.៣-យុទ្ធសាស្រ្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម.....១១

៤.៣.១-ផ្លូវថ្នល់.....១១

៤.៣.២-ផ្លូវទឹក.....១១

៤.៣.៣-ផ្លូវដែក.....១២

៤.៣.៤-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា.....១២

៤.៣.៥-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌.....១២

៤.៣.៦-ការផ្គត់ផ្គង់ទឹកស្អាត.....១២

៤.៤-យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក.....១៣

៤.៥-យុទ្ធសាស្រ្តអភិវឌ្ឍន៍សង្គមកិច្ច.....១៣

៤.៦-យុទ្ធសាស្រ្តការពារបរិស្ថាន និងធនធានធម្មជាតិ.....១៣

៤.៦.១-យុទ្ធសាស្រ្តគ្រប់គ្រងសំណល់រឹង.....១៣

៤.៦.២-យុទ្ធសាស្រ្តគ្រប់គ្រងសំណល់រាវ.....១៤

៤.៦.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន.....១៤

៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ.....១៥

៤.៧-យុទ្ធសាស្រ្តបង្ការទប់ស្កាត់គ្រោះមហន្តរាយ.....១៥

៤.៨-យុទ្ធសាស្រ្តពង្រឹងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន.....១៦

៥-ផែនការសកម្មភាព.....១៦

៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម.....១៧

៥.២- ការផ្សព្វផ្សាយ.....................................................................................................១៧
៥.៣- ការអនុវត្តគម្រោងតាមវិស័យ .....................................................................................១៧
៥.៣.១- ការអភិវឌ្ឍក្រុង.............................................................................................១៧
៥.៣.២- ការអភិវឌ្ឍវិស័យទេសចរណ៍ ..............................................................................១៨
៥.៣.៣- ការដឹកជញ្ជូន ................................................................................................១៩
៥.៣.៤- ការពង្រឹងវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផល ...................................................២០
៥.៣.៥- ការគ្រប់គ្រងបរិស្ថាន ........................................................................................២០
៥.៣.៦- ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត .......................................................................២០
៥.៣.៧- ការគ្រប់គ្រងសំណល់រឹង .....................................................................................២១
៥.៣.៨- ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ ....................................................២១
៥.៣.៩- ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍...........................................................២១
៥.៣.១០- ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ........................................................................២២
៥.៤- ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង..............................................................................២២
៥.៤.១- ការអនុវត្តរយៈពេលខ្លី ឬគម្រោងអាទិភាព...................................................................២២
៥.៤.២- ការអនុវត្តរយៈពេលមធ្យម..................................................................................២៤
៥.៤.៣- ការអនុវត្តរយៈពេលវែង .....................................................................................២៥
**៦-ធនធានហិរញ្ញវត្ថុ** ...................................................................................................**២៦**
**៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ**.......................................................................**២៦**
៧.១- យន្តការ...............................................................................................................២៦
៧.២- ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត.............................................................២៦
៧.៣- ភារកិច្ច នីតិវិធី និងគោលការណ៍.....................................................................................២៧
**៨-សេចក្ដីសន្និដ្ឋាន**.......................................................................................................**២៧**
**៩-អនុសាសន៍**..............................................................................................................**២៨**
**សន្ទានុក្រម**...............................................................................................................**២៩**
**ឯកសារឧបសម្ព័ន្ធ**.........................................................................................................**៣៣**

**១-សេចក្តីផ្តើម**

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ក្រុងកែប មានភូមិសាស្ត្រស្ថិតក្នុងតំបន់ឆ្នេរសមុទ្រនាទិសនិរតីនៃព្រះរាជាណាចក្រកម្ពុជា មានសមុទ្រ កោះ ឆ្នេរសមុទ្រ ព្រៃកោងកាង ស្រែអំបិល វាលទំនាប ខ្ពង់រាប ជម្រាលភ្នំ ភ្នំ គម្របព្រៃ ឧទ្យានជាតិ និងតំបន់ភ្នំវល្លិដែលមានសក្តានុពលខ្ពស់សម្រាប់ដំណាំម្រេចនិងធូរេន។ ក្រុងកែបស្ថិតនៅតាមបណ្តោយអ័ក្សនៃការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រអាស៊ានហាយវ៉េលេខ១២៣ និងមានចម្ងាយ១៦៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៣ លេខ៣១ លេខ៣៣ និងលេខ៣៣អា និងមានផ្លូវដែកឆ្លងកាត់ចំនួន១ ខ្សែ និងស្ថានីយអយស្ម័យយាន១ កន្លែង។

ក្រុងកែបជាទីក្រុងអេកូទេសចរណ៍ធម្មជាតិប្រណីតកម្រិតខ្ពស់នៃតំបន់ឆ្នេរសមុទ្រកម្ពុជា ជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក និងជាទីក្រុងដែលមានឈ្មោះល្បីល្បាញ ដែលបានទទួលពានរង្វាន់ទីក្រុងស្អាតផ្កាឈូក៣ទង ពានរង្វាន់ទីក្រុងនិរន្តរភាពបរិស្ថានអាស៊ាន ពានរង្វាន់ឡាបិលទីក្រុងទេសចរណ៍ស្អាតអាស៊ាន និងពានរង្វាន់កិត្តិយសជាច្រើនទៀត ជាគោលដៅទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រដែលមានសក្តានុពលសេដ្ឋកិច្ចសម្បូរបែប និងមានភ្ញៀវទេសចរជាតិនិងអន្តរជាតិរាប់លាននាក់ មកទស្សនាលម្ហែកម្សាន្តក្នុងមួយឆ្នាំៗ។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍន៍ក្រុងកែប ប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្ត និងក្រុងកែប ក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំនូវ **ប្លង់គោលប្រើប្រាស់ដីក្រុងកែបចក្ខុវិស័យឆ្នាំ២០៣០** ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសអភិវឌ្ឍន៍ដែនដីក្រុងកែបទាំងមូល ស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីក្រុងកែប ត្រូវបានកសាងឡើងដោយមានការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្មនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីក្រុងកែបមានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលជាមួយវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដីការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់កម្រិតក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានទឹកក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ជាពិសេសការអភិរក្សធនធានធម្មជាតិនិងជីវចម្រុះតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលអាចរងការបំផ្លាញដោយសារសកម្មភាពអភិវឌ្ឍខុសបទដ្ឋានបច្ចេកទេស ឬដោយសារប្រែប្រួលអាកាសធាតុ ដូចជា សំណឹកនៃឆ្នេរសមុទ្រ ការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅក្នុងទីក្រុង របបទឹកភ្លៀងមិនទៀងទាត់ ទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។

## ២-ចក្ខុវិស័យ

### ២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម

ប្លង់គោលប្រើប្រាស់ដីក្រុងកែប ត្រូវបានរៀបចំឡើងដោយបានប្រមូល សិក្សា និងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សមស្របតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី (សៀវភៅស ដីធ្លី) និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ដើម្បីកំណត់ចក្ខុវិស័យដល់ឆ្នាំ២០៣០ ប្លង់គោលប្រើប្រាស់ដីក្រុងកែប ត្រូវបានសិក្សាក្របខណ្ឌសេដ្ឋកិច្ច សង្គម ដោយផ្អែកលើសក្តានុពលសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រតំបន់ឆ្នេរសមុទ្រកម្ពុជា ក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គោលនយោបាយដីធ្លី (សៀវភៅស ដីធ្លី) គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀតរបស់រាជរដ្ឋាភិបាល និងរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ ដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ក្រុងកែបមានផ្ទៃដីទំហំ៧ ៩៤៩ ហិកតា ចំនួនប្រជាជននៅឆ្នាំ២០០៨ មានចំនួន១២ ៧០៥ នាក់ ឆ្នាំ

២០១៨ មានចំនួន២១ ២២៨ នាក់ និងនៅឆ្នាំ២០៣០ នឹងកើនឡើងដល់២៣ ៥០៣ នាក់ ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ជាមួយគ្នានេះ ការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ក្រុងកែបនៅឆ្នាំ២០០៨ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមាន៤ ០៤៣ នាក់(៦២,២៦%) ក្នុងវិស័យឧស្សាហកម្មធុនស្រាលដែលជាសិប្បកម្មមាន៥២៨ នាក់ (៨,១%) និងក្នុងវិស័យសេវាកម្មមាន១ ៩២៦ នាក់ (២៩,៦៤%) ហើយរំពឹងថានៅឆ្នាំ២០៣០ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមានការកើនឡើងដល់៦ ៧៦៩ នាក់ (៤៨%) ក្នុងវិស័យឧស្សាហកម្មធុនស្រាលដែលជាសិប្បកម្មមានការកើនឡើងដល់ចំនួន១ ៤១០ នាក់ (១០%) និងក្នុងវិស័យសេវាកម្មមានការកើនឡើងដល់ចំនួន៥ ៩២៣ នាក់(៤២%)។

### ២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៣០ នៃប្លង់គោលប្រើប្រាស់ដីក្រុងកែប គឺសំដៅរៀបចំនិងអភិវឌ្ឍ **«ក្រុងកែបជាទីក្រុងទំនើបមានខ្យល់អាកាសធម្មជាតិបរិសុទ្ធ ឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក សម្រាប់ការស្នាក់នៅ ប្រកបការងារ និងទេសចរណ៍ ដែលមានគុណភាពបរិស្ថានរស់នៅល្អ ជាសុកភាព និងសុភមង្គលល្អ តាមរយៈការអភិវឌ្ឍជាទីក្រុង ១).គោលដៅទេសចរណ៍ឆ្នេរសមុទ្រ កោះ ធម្មជាតិ ដែលស្អាតបំផុតលើសកលលោក, ២).ទីក្រុងបៃតង បុរីលំនៅឋានស្ងប់ស្ងាត់ មជ្ឈមណ្ឌលការងារ ធុរកិច្ច អប់រំ សិក្សា ស្រាវជ្រាវ ដែលមានហេដ្ឋារចនាសម្ព័ន្ធសេវាកម្ម និងគុណភាពបរិស្ថានរស់នៅបៃតងធម្មជាតិល្អប្រណីត ប្រកបដោយសុភមង្គល, ៣).គ្រប់គ្រង និងអភិបាលកិច្ចល្អ, ៤).ចីរភាព តុល្យភាព និងសមាហរណកម្មការអភិវឌ្ឍ ប្រកបដោយទឹកសមុទ្រខៀវស្រងាត់ និងខ្យល់អាកាសល្អបរិសុទ្ធ, និង ៥).ជ័យលាភីទីក្រុងឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ដែលមានភ្ញៀវទេសចរជាតិ និងអន្តរជាតិមកសម្រាកលំហែកម្សាន្តគ្រប់រដូវកាល»**។

## ៣-គោលបំណង និងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងកែប មានគោលបំណង និងគោលដៅដូចខាងក្រោម៖

### ៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីក្រុងកែប មានគោលបំណង៖

- តម្រង់ទិសការប្រើប្រាស់ដី ធនធានធម្មជាតិ និងការរៀបចំនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ធានាសន្តិសុខស្បៀង កិច្ចការពារជាតិ និងលំនឹងធម្មជាតិ
- តម្រង់ទិសការកែលម្អនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គម និងសេដ្ឋកិច្ច ឆ្ពោះទៅរកសមាហរណកម្មល្អ ក្នុងក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ
- លើកកម្ពស់អត្តសញ្ញាណវប្បធម៌ជាតិ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។

### ៣.២- គោលដៅ

ប្លង់គោលប្រើប្រាស់ដីក្រុងកែប មានគោលដៅ៖

- កំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍នគរូបនីយកម្មប្រកបដោយចីរភាពនិងតុល្យភាព
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ច និងទាក់ទាញការគាំទ្រការវិនិយោគ
- គ្រប់គ្រង ការពារ ប្រើប្រាស់ អភិវឌ្ឍដី និងធនធានធម្មជាតិ ដោយកំណត់ឱ្យបានច្បាស់លាស់ជាមុននូវតំបន់សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គម សេដ្ឋកិច្ច បរិស្ថាន និងវប្បធម៌
- ធ្វើសមាហរណកម្មការគ្រប់គ្រងដីនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មក្រុង ស្រុក ខេត្ត និងថ្នាក់ជាតិ
- លើកកម្ពស់ជីវភាពប្រជាជនក្នុងក្រុងឱ្យកាន់តែប្រសើរឡើងនិងផ្សារភ្ជាប់ទំនាក់ទំនងរវាងតំបន់ទីក្រុងនិងជនបទ
- ទប់ស្កាត់និងបង្ការហានិភ័យនៃគ្រោះធម្មជាតិនិងការប្រែប្រួលអាកាសធាតុ
- ធ្វើសមាហរណកម្មអត្តសញ្ញាណវប្បធម៌ជាតិនិងធម្មជាតិទៅក្នុងការអភិវឌ្ឍស្របតាមទីតាំងភូមិសាស្ត្រតំបន់ឆ្នេរសមុទ្រ។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សក្រុងកែប

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងកែប បានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ច និងការធ្វើសមាហរណកម្ម ការអភិវឌ្ឍនិងការអភិរក្ស ប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ ដូចខាងក្រោម៖

### ៤.១- យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព

#### ៤.១.១-ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម

##### ក)-តំបន់ក្រុងបច្ចុប្បន្ន

- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលក្រុង សង្កាត់ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- ជំរុញដាក់លេខផ្ទះ និងឈ្មោះឬលេខផ្លូវ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង
- ជំរុញការគ្រប់គ្រងនិងកែលម្អឆ្នេរសមុទ្រកម្សាន្តសម្រាប់បម្រើវិស័យទេសចរណ៍
- កែលម្អ និងស្តារបណ្តាញហេដ្ឋារចនាសម្ព័ន្ធរួមមានផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី ការប្រមូលសំណល់រឹងនិងរាវ ឱ្យមានលក្ខណៈសមស្រប និងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភ័ណភាពក្រុង
- ជំរុញការអភិវឌ្ឍដីឡូត៍ដែលមិនទាន់បានប្រើប្រាស់ ឱ្យធ្វើការអភិវឌ្ឍ និងប្រើប្រាស់ឱ្យបានចំទិសដៅ និងមុខងារ ប្រកបដោយចីរភាព

- កែលម្អ និងពង្រីកផ្លូវជាតិលេខ៣៣អា វិថី អនុវិថី ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន ចិញ្ចើមផ្លូវ ភ្លើងបំភ្លឺ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម កំណត់ប្រភេទដើមឈើនិងដាំដើមឈើ រៀបចំសួនច្បារតាមបណ្ដោយផ្លូវ សួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង នៅក្នុងក្រុងកែបស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភ័ណភាពរស់រវើក សណ្ដាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយផាសុកភាពសម្រាប់មនុស្សទាំងអស់គ្នា
- គ្រប់គ្រង អភិវឌ្ឍ និងអភិរក្សអគារព្រះរាជដំណាក់ព្រះរាជដំណាក់សម្ដេចព្រះមហាក្សត្រិយានីស៊ីសុវត្ថិមុនីវង្សកុសុមនារីរ័ត្ន
- រៀបចំនិងកំណត់រចនាបថអគារ ពណ៌អគារ និងរបង ឱ្យមានសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ ជាទីក្រុងទេសចរណ៍ ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ ប្លង់លម្អិតនគរូបនីយកម្ម តាមតំបន់នីមួយៗ។

**ខ)-ទិសដៅនគរូបនីយកម្ម**

- និន្នាការនៃការអភិវឌ្ឍទីក្រុងនិងនគរូបនីយកម្មមានលទ្ធភាពពង្រីកទៅកាន់តំបន់ភាគខាងកើត និងខាងជើងនៃទីក្រុងបច្ចុប្បន្ន
- គ្រប់គ្រងការអភិវឌ្ឍ និងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងការអភិវឌ្ឍរូបវន្តជាពិសេសបណ្ដាញផ្លូវ ប្រព័ន្ធលូ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងចៀសវាងការសាងសង់មុនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ពង្រឹងសមត្ថភាពមន្ត្រីក្នុងការធ្វើផែនការអភិវឌ្ឍនិងគ្រប់គ្រងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព ជាពិសេសគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តនិងក្រុង ដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល ជាសេនាធិការក្នុងការគ្រប់គ្រង និងអនុវត្តការងាររៀបចំដែនដីនិងនគរូបនីយកម្ម។

### ៤.១.២- យុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ដី

ក្រុងកែបមានផ្ទៃដីប្រមាណ៧ ៩៤៩ ហិកតា ក្នុងឆ្នាំ២០១៨ និងមានផ្ទៃដីប្រមាណ៨ ០៦១ ហិកតា នៅឆ្នាំ២០៣០ ត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺ ប្រភេទដីកម្រិតការសាងសង់ និងប្រភេទដីអាចសាងសង់បាន។ ប្រភេទដីកម្រិតការសាងសង់មានផ្ទៃដីប្រមាណ៦ ២២៤ ហិកតា ស្មើនឹង៧៨% ក្នុងឆ្នាំ២០១៨ និងមានផ្ទៃដីប្រមាណ៥ ៦៨០ ហិកតា ស្មើនឹង៧០% នៅឆ្នាំ២០៣០។ ប្រភេទដីអាចសាងសង់បានមានផ្ទៃដីប្រមាណ១ ៧២៥ ហិកតា ស្មើនឹង២២% ក្នុងឆ្នាំ២០១៨ និងមានផ្ទៃដីប្រមាណ២ ៣៨១ ហិកតា ស្មើនឹង៣០% នៅឆ្នាំ២០៣០។

## ក)- ប្រភេទដីកម្រិតការសាងសង់

ផ្អែកតាមច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ស្ដីពីការកំណត់តំបន់ឧទ្យានជាតិកែប និងសារាចរណែនាំលេខ០១ ស.រ.ណ.ន. ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានគតិយុត្តជាធរមាន ប្រភេទដីកម្រិតការសាងសង់ត្រូវបានកំណត់ជាតំបន់ ដូចខាងក្រោម៖

១- តំបន់កសិកម្ម មានផ្ទៃដីប្រមាណ៣ ១៣២ ហិកតា ស្មើនឹង៥២% ស្ថិតនៅសង្កាត់កែប សង្កាត់ព្រៃធំ និងសង្កាត់អូរក្រសារ មានជាអាទិ៍ ស្រែ ចម្ការស្វាយ ចម្ការម្រេច ចម្ការធុរេន

២- តំបន់ព្រៃឈើ មានផ្ទៃដីប្រមាណ១ ០៥៤ ហិកតា ស្មើនឹង១៩% ស្ថិតនៅមួយភាគតូចនៃភ្នំវល្លិ ក្នុងសង្កាត់ព្រៃធំ មានព្រៃឈើ និងព្រៃរបោះ

៣- តំបន់ធនធានទឹក មានផ្ទៃដីប្រមាណ៥៥ ហិកតា ស្មើនឹង១% មានទំនប់ប៉ោហេង ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ និងទំនប់អូរក្រសារ ស្ថិតនៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ និងភូមិអូរក្រសារ សង្កាត់អូរក្រសារ

៤- តំបន់ការពារ រួមមាន៖

- ឧទ្យានជាតិកែប មានផ្ទៃដីប្រមាណ៩៨១ ហិកតា ស្មើនឹង២០%
- ឆ្នេរសមុទ្រ និងដីចំណីឆ្នេរសមុទ្រ មានផ្ទៃដីប្រមាណ២០ ហិកតា ស្មើនឹង០,៥% និងកោះចំនួន១៣ មានផ្ទៃដីប្រមាណ២៦០ ហិកតា
- ព្រៃកោងកាង មានផ្ទៃដីប្រមាណ១៩១ ហិកតា ស្មើនឹង៣% ស្ថិតនៅតាមបណ្ដោយឆ្នេរសមុទ្រ ពីចំណុចព្រំប្រទល់សង្កាត់អូរក្រសារ និងស្រុកទឹកឈូ ខេត្តកំពត រហូតមកដល់ចំណុចព្រំប្រទល់សង្កាត់កែប និងឃុំពងទឹក ស្រុកដំណាក់ចង្អើរ
- តំបន់ស្រែអំបិល មានផ្ទៃដីប្រមាណ២២២ ហិកតា ស្មើនឹង៤% ស្ថិតនៅសង្កាត់អូរក្រសារ សង្កាត់ព្រៃធំ និងសង្កាត់កែប។

៥- តំបន់ផ្សេងៗ មានផ្ទៃដីប្រមាណ២៥ ហិកតា ស្មើនឹង០,៥% មានតំបន់ទុកដាក់សំរាម មានផ្ទៃដីប្រមាណ ១៤ ហិកតា ស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ដែលមានចម្ងាយប្រមាណ ១២ គីឡូម៉ែត្រពីសាលាខេត្តកែប និងតំបន់អាងប្រព្រឹត្តកម្មទឹកកខ្វក់មានផ្ទៃដីប្រមាណ ១១ ហិកតា ក្នុងនោះ ១ កន្លែងស្ថិតនៅសង្កាត់កែប និង ១ កន្លែងទៀតស្ថិតនៅសង្កាត់ព្រៃធំ។

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីនេះ តម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុន ស្របតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការអភិវឌ្ឍដី។

មានតែតំបន់កសិកម្មប៉ុណ្ណោះដែលអាចអនុញ្ញាតឱ្យសាងសង់លំនៅឋានផ្ទាល់ខ្លួនបានដែលមិនមានលក្ខណៈអាជីវកម្ម និងអាចសាងសង់រោងសិប្បកម្មសម្រាប់គោលដៅកសិកម្មបានដោយមិនបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់កសិកម្មត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង០,៥ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង១០% ឆ្លាតគម្លាតអគារខាងមុខយ៉ាងតិច១០ ម៉ែត្រ និងចំហៀងសងខាងនិងខាងក្រោយយ៉ាងតិចស្មើនឹងពាក់កណ្តាលគម្លាតអគារខាងមុខ កម្ពស់អគារអតិបរមាស្មើនឹង៨ ម៉ែត្រ សួនច្បារជ្រាបទឹកនិងផ្ទៃបៃតងយ៉ាងតិច៦៥% នៃផ្ទៃដីដែលនៅសល់ពីការសាងសង់ និងដាំដើមឈើយ៉ាងតិច ១ ដើមសម្រាប់ផ្ទៃក្រឡាដីឡូត៍៤៩ ម៉ែត្រក្រឡា។

**ខ)- ប្រភេទដីអាចសាងសង់បាន**

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីក្រុងកែបចក្ខុវិស័យឆ្នាំ២០៣០ ប្រភេទដីអាចសាងសង់បានត្រូវបានកំណត់ជាតំបន់។ បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់នីមួយៗត្រូវមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ការដាំដើមឈើ ជួរតម្រង់ ឆ្លាតគម្លាត កម្ពស់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភ័ណភាព និងមានរចនាបថស្ថាបត្យកម្មខ្មែរ និង/ឬមានធម្មជាតិត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន និងបែងចែកជាតំបន់ប្រើប្រាស់ដី ដូចខាងក្រោម៖

១- តំបន់លំនៅឋាន មានផ្ទៃដីប្រមាណ១ ០៨៦ ហិកតា ស្មើនឹង៤៥% ស្ថិតនៅផ្នែកខាងកើតនៃសង្កាត់កែប ផ្នែកខាងត្បូង និងផ្នែកខាងជើងនៃឧទ្យានជាតិកែប អមសងខាងផ្លូវជាតិលេខ ៣៣អា តាមបណ្តោយផ្លូវប្រូបមាត់សមុទ្រ ផ្នែកខាងលិចនៃសង្កាត់ព្រៃធំ និងតាមបណ្តោយផ្លូវជាតិលេខ៣៣ ក្នុងសង្កាត់អូរក្រសារ។ តំបន់លំនៅឋានត្រូវបានកំណត់បែងចែកជា៖
   - តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥
   - តំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥
   - តំបន់លំនៅឋានដែលមានកម្ពស់មធ្យមត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០
   - តំបន់លំនៅឋានចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០។

២- តំបន់ពាណិជ្ជកម្ម មានផ្ទៃដីប្រមាណ១៦៧ ហិកតា ស្មើនឹង៧% ស្ថិតនៅសង្កាត់ព្រៃធំ សង្កាត់អូរក្រសារ និងសង្កាត់កែប ត្រង់រង្វង់មូលសេះស ត្រង់ចំណុចបំបែកផ្លូវជាតិលេខ ៣៣អា ខាងកើតផ្លូវជាតិលេខ៣៣អា ចាប់ពីរង្វង់មូលព្រះឥសូរ រហូតដល់រង្វង់មូលព្រះវិស្ណុ ត្រង់តំបន់ជាប់នឹងអនុវិទ្យាល័យ ហ៊ុន សែន កែប និងត្រង់តំបន់ផ្សារក្តាម។ តំបន់ពាណិជ្ជកម្មត្រូវបានកំណត់បែងចែកជា៖
   - តំបន់ពាណិជ្ជកម្មត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៦,០
   - តំបន់ពាណិជ្ជកម្មចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០។

៣- តំបន់សិប្បកម្ម៖ ក្រុងកែបមិនមានតំបន់ឧស្សាហកម្មទេ គឺមានតែតំបន់សិប្បកម្មផលិតផលកសិកម្មនិងជលផល ស្ថិតនៅក្នុងសង្កាត់កែប សង្កាត់ព្រៃធំ និងសង្កាត់អូរក្រសារ មានជាអាទិ៍ សិប្បកម្មលក្ខណៈគ្រួសារផលិតទឹកបរិសុទ្ធ ផលិតទឹកត្រី បកសាច់ក្តាម។ តំបន់សិប្បកម្មត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥

៤- តំបន់ចម្រុះ មានផ្ទៃដីប្រមាណ២៥ ហិកតា ស្មើនឹង ១% ស្ថិតនៅជុំវិញឧទ្យានសម្តេចតេជោ និងតំបន់រដ្ឋបាល ក្នុងសង្កាត់កែប។ តំបន់ចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៥,០

៥- តំបន់ដឹកជញ្ជូន មានផ្ទៃដីប្រមាណ៨២០ ហិកតា ស្មើនឹង៣៥% រួមមានកំពង់ផែទេសចរណ៍កែប ស្ថិតនៅភូមិកែប សង្កាត់កែប ស្ថានីយអយស្ម័យយាន ស្ថិតនៅសង្កាត់អូរក្រសារ និងបណ្តាញផ្លូវទាំងអស់ក្នុងក្រុង។ ក្រុងកែបនឹងគ្រោងរៀបចំបន្ថែមចំណតរថយន្តចំនួន០៥ កន្លែង ក្នុងនោះចំនួន០៣ កន្លែង ស្ថិតក្នុងសង្កាត់កែប និងចំនួន០២ កន្លែងទៀត ស្ថិតក្នុងសង្កាត់ព្រៃធំ ដែលនឹងត្រូវរៀបចំនៅលើដីចាក់បំពេញថ្មី។ តំបន់ដឹកជញ្ជូនត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០

៦- តំបន់ទេសចរណ៍ មានផ្ទៃដីប្រមាណ១៨១ ហិកតា ស្មើនឹង៧% ស្ថិតនៅសង្កាត់ព្រៃធំ សង្កាត់អូរក្រសារ និងសង្កាត់កែប ត្រង់តំបន់ជើងនិងជម្រាលភ្នំ ជាប់ឧទ្យានជាតិកែប តាមបណ្តោយឆ្នេរសមុទ្រ និងជាប់នឹងតំបន់ស្រែអំបិល មានជាអាទិ៍តំបន់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន រមណីយដ្ឋាន។ តំបន់ទេសចរណ៍ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០

៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ មានផ្ទៃដីប្រមាណ១៧ ហិកតា ស្មើនឹង១% ស្ថិតក្នុងសង្កាត់កែប សង្កាត់ព្រៃធំ និងសង្កាត់អូរក្រសារ មានជាអាទិ៍សាលាខេត្ត សាលាក្រុង សាលាសង្កាត់ សាលាដំបូង មន្ទីរ អង្គភាពជុំវិញខេត្ត ទីបញ្ជាការដ្ឋាន ស្នងការដ្ឋាន អធិការដ្ឋាន ប៉ុស្តិ៍នគរបាល សាលារៀន មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព សារៈមន្ទីរ ប៉ុស្តិ៍ប្រៃសណីយ បណ្ណាល័យ។ តំបន់រដ្ឋបាលនិងសេវាសាធារណៈត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០

៨- តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង មានផ្ទៃដីប្រមាណ២២ ហិកតា ស្មើនឹង១% រួមមានឧទ្យានសម្តេចតេជោ សួនច្បារសាធារណៈនៅមុខសាលាខេត្តកែប ទីលានកីឡដ្ឋាន។ ក្រៅពីនេះមានសួនច្បារសាធារណៈនៅតាមបណ្តោយឆ្នេរសមុទ្រ បណ្តាញបៃតងតាមចិញ្ចើមផ្លូវ ឧទ្យានជាតិកែប និងលម្ហសាធារណៈនិងផ្ទៃបៃតងជាច្រើនទៀត។ តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង០,១

៩- តំបន់វប្បធម៌និងសាសនា មានផ្ទៃដីប្រមាណ៦៣ ហិកតា ស្មើនឹង៣% ស្ថិតក្នុងសង្កាត់កែប សង្កាត់ព្រៃធំ និងសង្កាត់អូរក្រសារ មានជាអាទិ៍វត្តអារាមព្រះពុទ្ធសាសនា ព្រះវិហារសាសនាភ្នំសរសៀរ ទួលបុរាណ ទីសក្ការបូជា វាលសួសាន។ តំបន់វប្បធម៌និងសាសនាត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង២,០។

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីនេះ តម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន ស្របតាមអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ